**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ០១៥ ស.ណ.ន

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ២០០៩

# សេចក្តីណែនាំ

## ស្តីពី

## ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

អនុលោមតាមមាត្រា ៦៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ និងស្មារតីអង្គប្រជុំសាមញ្ញលើកទី២ នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អំពីគោលការណ៍នៃការរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុង ដូចខាងក្រោម :

### ១. អំពីការរៀបចំបទបញ្ជាផ្ទៃក្នុង

បន្ទាប់ពីអង្គប្រជុំចូលកាន់តំណែងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់នូវវិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើតាមទម្រង់ជាដីកា និងត្រូវអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ ដែលប្រព្រឹត្តទៅមិនឱ្យមុនម្ភៃប្រាំ (២៥) ថ្ងៃ ឬលើសពីសាមសិបប្រាំ (៣៥) ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី១។

ដើម្បីឱ្យក្រុមប្រឹក្សាមានមូលដ្ឋានក្នុងការរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុងឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ក្រសួងមហាផ្ទៃបានរៀបចំគំរូបទបញ្ជាផ្ទៃក្នុង ដែលទទួលបានការអនុម័តទទួលស្គាល់ពី គ.ជ.អ.ប នៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ នាថ្ងៃទី២២ ខែមេសា ឆ្នាំ ២០០៩ ដូចមានភ្ជាប់មកជាមួយសេចក្តីណែនាំនេះ។

គំរូបទបញ្ជាផ្ទៃក្នុងនេះ គ្រាន់តែជាឯកសារមូលដ្ឋានសម្រាប់ឱ្យក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពិនិត្យ ពិចារណា និងរៀបចំនូវបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនឱ្យបានសមស្របតាមគោលការណ៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ខ្លឹមសារនៃគំរូបទបញ្ជាផ្ទៃក្នុងនេះ បានចែងនូវលក្ខខណ្ឌជាអប្បបរមាក្នុងការកំណត់នូវវិធានទាំងឡាយសម្រាប់ដំណើរការប្រជុំ និងរបៀបរបបធ្វើការងាររបស់ក្រុមប្រឹក្សា

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួនតែប៉ុណ្ណោះ។ ផ្អែកតាមគំរូបទបញ្ជាផ្ទៃក្នុងនេះ ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការពិនិត្យ ឬកែលំអ បំពេញបន្ថែម ឱ្យ ស្របតាមស្ថានភាពជាក់ស្តែងនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន និងឱ្យស្របតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីដាក់ចេញជាបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

## ២. នីតិវិធីរៀបអនុម័តបទបញ្ជាផ្ទៃក្នុង

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំពិភាក្សា និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយអនុវត្តតាមលក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា ៦៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ការប្រជុំអនុម័តបទបញ្ជាផ្ទៃក្នុងនេះមានសុពលភាពបាន លុះត្រាតែមានសមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូលចូលរួម ហើយត្រូវអនុម័តដោយសម្លេងលើសពីពាក់កណ្តាល នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។ ក្នុងករណីមានសម្លេងអនុម័តស្មើគ្នា សម្លេងរបស់ប្រធានអង្គប្រជុំ មានឧត្តមានុភាព។

បានសេចក្តីថា :

- បើក្រុមប្រឹក្សាមានសមាជិកចំនួន ២១ រូប ត្រូវមានសមាជិកចំនួនយ៉ាងតិច ១១ រូបចូលរួម ហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេងយល់ព្រមយ៉ាងតិច ១១ សម្លេង។
- បើក្រុមប្រឹក្សាមានសមាជិកចំនួន ១៩ រូប ត្រូវមានសមាជិកចំនួនយ៉ាងតិច ១០ រូបចូលរួម ហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេងយល់ព្រមយ៉ាងតិច ១០ សម្លេង។
- បើក្រុមប្រឹក្សាមានសមាជិកចំនួន ១៧ រូប ត្រូវមានសមាជិកចំនួនយ៉ាងតិច ០៩ រូបចូលរួម ហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេងយល់ព្រមយ៉ាងតិច ០៩ សម្លេង។
- បើក្រុមប្រឹក្សាមានសមាជិកចំនួន ១៥ រូប ត្រូវមានសមាជិកចំនួនយ៉ាងតិច ០៨ រូបចូលរួម ហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេងយល់ព្រមយ៉ាងតិច ០៨ សម្លេង។
- បើក្រុមប្រឹក្សាមានសមាជិកចំនួន ១៣ រូប ត្រូវមានសមាជិកចំនួនយ៉ាងតិច ០៧ រូបចូលរួម ហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេងយល់ព្រមយ៉ាងតិច ០៧ សម្លេង។
- បើក្រុមប្រឹក្សាមានសមាជិកចំនួន ១១ រូប ត្រូវមានសមាជិកចំនួនយ៉ាងតិច ០៦ រូបចូលរួម ហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេងយល់ព្រមយ៉ាងតិច ០៦ សម្លេង។
- បើក្រុមប្រឹក្សាមានសមាជិកចំនួន ០៩ រូប ត្រូវមានសមាជិកចំនួនយ៉ាងតិច ០៥ រូបចូលរួម ហើយត្រូវបោះឆ្នោតអនុម័តដោយសម្លេងយល់ព្រមយ៉ាងតិច ០៥ សម្លេង។

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវចាត់តាំងមន្ត្រីមួយរូបឱ្យធ្វើកំណត់ហេតុអង្គប្រជុំអនុម័តបទបញ្ជាផ្ទៃក្នុងឱ្យបានត្រឹមត្រូវ។ ក្រោយពីបានអនុម័តរួចហើយ ត្រូវរៀបចំចម្លងបទបញ្ជាផ្ទៃក្នុងនេះ ដើម្បីចែកជូនគ្រប់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្ញើជូនក្រសួង មហាផ្ទៃ និងរក្សា

ទុកជាឯកសារ ។ ក្នុងករណីមានការកែប្រែ ក្រសួងមហាផ្ទៃនឹងពិនិត្យមើលអំពីខ្លឹមសារនៃការកែប្រែនោះ ។ ក្នុងករណីខ្លឹមសារនៃការកែប្រែនោះ ផ្ទុយពីគោលការណ៍ច្បាប់ លិខិតបទដ្ឋាន ដែលនៅជាធរមាន ក្រសួងមហាផ្ទៃនឹងធ្វើការណែនាំឱ្យក្រុមប្រឹក្សានោះធ្វើការកែតម្រូវឡើងវិញជាបន្ទាន់ ។ ក្រោយពីបានទទួលការណែនាំពីក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាត្រូវធ្វើការកែតម្រូវឡើងវិញនៅក្នុងកិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញបន្ទាប់ ។

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់ ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ខេង**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នចំណុះរាជរដ្ឋាភិបាលកម្ពុជា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

*"ដើម្បីជូនជ្រាប"*

- លេខាធិការដ្ឋាន គ.ជ.អ.ប
- អង្គភាពចំណុះទីស្តីការក្រសួងមហាផ្ទៃ
- សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

*"ដើម្បីអនុវត្ត"*

- ឯកសារ- កាលប្បវត្តិ

គំរូបទបញ្ជាផ្ទៃក្នុង

# ដីកា

# ស្តីពី

# បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុម ប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- យោងតាមការអនុម័តរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី..... ក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ នាថ្ងៃទី......... ខែ............ឆ្នាំ ២០០.... ។

## សម្រេច

# ជំពូកទី ១

# អំពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សា

**ប្រការ ១.—**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានពីរប្រភេទគឺ **កិច្ចប្រជុំសាមញ្ញ** និង**កិច្ចប្រជុំវិសាមញ្ញ** ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ជាសម័យប្រជុំរបស់ក្រុមប្រឹក្សា។ រយៈពេលនៃសម័យប្រជុំនីមួយៗរបស់ក្រុមប្រឹក្សាគឺអាស្រ័យលើរបៀបវារៈនៃសម័យប្រជុំរបស់ក្រុមប្រឹក្សា។

**ប្រការ ២.—**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រជុំសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនយ៉ាងហោចណាស់ ចំនួនដប់ពីរ(១២) ដង ជារៀងរាល់ឆ្នាំ។

កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនត្រូវប្រារព្ធធ្វើឡើងមុនម្ភៃប្រាំ (២៥) ថ្ងៃ និងលើសពីសាមសិបប្រាំ (៣៥) ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុនឡើយ។

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុម័តប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនសំរាប់រយៈពេលដប់ពីរ (១២)ខែ មិនឱ្យហួសពីកិច្ចប្រជុំសាមញ្ញលើកទី ២ និងប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញលើកក្រោយៗទៀតក្នុងរយៈពេលដប់ពីរ (១២) ខែម្តងៗ ដោយបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងឱ្យបានជាក់លាក់។

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវផ្សព្វផ្សាយជាសាធារណៈនូវប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនក្នុងរយៈពេលមិនឱ្យលើសពីបី(០៣) ថ្ងៃ បន្ទាប់ពីក្រុមប្រឹក្សាបានអនុម័ត ។

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ត្រូវតែអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនេះ ។

អង្គប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែក្នុងករណីចាំបាច់ដែលក្រុមប្រឹក្សាត្រូវប្រជុំជាសម្ងាត់ ដូចមានចែងក្នុងប្រការ ៧ នៃបទបញ្ជាផ្ទៃក្នុងនេះ។

**ប្រការ ៣.—**

ប្រធានក្រុមប្រឹក្សាជាអ្នកកោះអញ្ជើញសមាជិករបស់ខ្លួនឱ្យចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា។

គ្រប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ត្រូវមានលិខិតអញ្ជើញ ដែលត្រូវប្រគល់ជូនសមាជិកគ្រប់រូបនៃក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធនានា ក្នុងរយៈពេលបី(០៣) ថ្ងៃការងារ មុនកិច្ចប្រជុំចាប់ផ្តើម។

លិខិតអញ្ជើញត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទីកន្លែង កាលបរិច្ឆេទ (ម៉ោង ថ្ងៃ ខែ ឆ្នាំ) និងរបៀបវារៈនៃកិច្ចប្រជុំ ព្រមទាំងត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា ប្រសិនបើមាន។

**ប្រការ ៤.–**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចកោះប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬ ពិសេសណាមួយ ។

ប្រធានក្រុមប្រឹក្សា ឬ សមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី(១/៣) នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល អាចស្នើសុំឱ្យមានកិច្ចប្រជុំវិសាមញ្ញបាន ។

លិខិតអញ្ជើញ និងរបៀបវារៈសម្រាប់កិច្ចប្រជុំវិសាមញ្ញ ត្រូវចែកជូនដល់សមាជិកក្រុមប្រឹក្សាគ្រប់រូប ឱ្យបានយ៉ាងតិចពីរ(០២) ថ្ងៃការងារ មុនកិច្ចប្រជុំចាប់ផ្តើម ។

**ប្រការ ៥.–**

ប្រធានក្រុមប្រឹក្សា អភិបាល គណៈអភិបាល សមាជិកក្រុមប្រឹក្សាមួយភាគបី(១/៣) នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាអាចស្នើសុំដាក់បញ្ចូលរបៀបវារៈសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាបាន ។

ប្រធានក្រុមប្រឹក្សា ដោយមានការពិគ្រោះយោបល់ជាមួយអភិបាល ត្រូវរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំសម្រាប់សម័យប្រជុំនីមួយៗរបស់ក្រុមប្រឹក្សា ដើម្បីដាក់ជូនក្រុមប្រឹក្សាអនុម័ត ។

**ប្រការ ៦.–**

កាលបរិច្ឆេទ និងទីកន្លែងប្រជុំរបស់ក្រុមប្រឹក្សាត្រូវបិទផ្សាយនៅលើក្តារខៀនព័ត៌មានសាធារណៈរបស់ក្រុមប្រឹក្សា ព្រមទាំងមធ្យោបាយផ្សព្វផ្សាយនានាដែលមាននៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**ប្រការ ៧.–**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចប្រជុំជាសម្ងាត់បាន ស្របតាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ២

## អំពីរបៀបរបបប្រជុំរបស់ក្រុមប្រឹក្សា

**ប្រការ ៨.–**

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងមានសុពលភាពទៅបាន លុះត្រាតែមានវត្តមានសមាជិកក្រុមប្រឹក្សាមិនតិចជាងពាក់កណ្តាល នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ។

**ប្រការ ៩.–**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវដំណើរការកិច្ចប្រជុំរបស់ខ្លួនតាមនីតិវិធីដូចខាងក្រោម ៖

១- ពិនិត្យកូរ៉ុមសម្រាប់កិច្ចប្រជុំ

២- ពិនិត្យ និងអនុម័តរបៀបវារៈនៃកិច្ចប្រជុំ ដែលមានជាអាទិ៍ :

- ពិនិត្យ និងអនុម័តលើកំណត់ហេតុនៃកិច្ចប្រជុំលើកមុន
- ពិនិត្យ ពិភាក្សា និងអនុម័តលើប្រធានបទនីមួយៗដែលមាននៅក្នុងរបៀបវារៈ
- ពិនិត្យ ពិភាក្សា និងអនុម័តលើបញ្ហាផ្សេងៗ។

៣- ប្រកាសជូនព័ត៌មានអំពីកាលបរិច្ឆេទ និងទីកន្លែងជាក់លាក់នៃកិច្ចប្រជុំលើកក្រោយ ។

**ប្រការ ១០.–**

ក្នុងករណីមានបញ្ហាអ្វីដែលត្រូវលើកឡើង ឬជម្រាបជូនអង្គប្រជុំ ប្រធានអង្គប្រជុំអាចថ្លែងសេចក្តីនោះ មុននឹងចាប់ផ្តើមប្រជុំតាមរបៀបវារៈ ។

**ប្រការ ១១.–**

ក្នុងពេលកំពុងដំណើរការកិច្ចប្រជុំ បើប្រធានអង្គប្រជុំពិនិត្យឃើញថា កូរ៉ុមនៃកិច្ចប្រជុំមិនគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ៨ នៃបទបញ្ជាផ្ទៃក្នុងនេះទេ ប្រធានអាចផ្អាកការប្រជុំបាន ។ ការប្រជុំបន្ត ត្រូវធ្វើឡើងនៅថ្ងៃធ្វើការងារបន្ទាប់រហូតដល់អស់របៀបវារៈនៃកិច្ចប្រជុំដែលបានអនុម័តរួចហើយ ។

**ប្រការ ១២.–**

សមាជិកម្នាក់ៗនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានបំណងបញ្ចេញមតិ យោបល់ត្រូវលើកដៃសុំការអនុញ្ញាតពីប្រធានអង្គប្រជុំ ។

រយៈពេលបញ្ចេញមតិរបស់សមាជិកម្នាក់ៗ ក្នុងមួយលើកៗមិនលើសពី១៥នាទី ហើយត្រូវមានមតិតែពីបញ្ហាដែលកំពុងពិភាក្សា។ ប្រធានអង្គប្រជុំអាចអនុញ្ញាតបន្ថែមពេល៥នាទីទៀតបាន ប្រសិនបើយល់ឃើញថាជាការមានប្រយោជន៍ដល់បញ្ហាដែលកំពុងពិភាក្សា។ ការបន្ថែមនេះ អាចអនុញ្ញាតឱ្យបន្តបាន ២ដង ក្នុងបញ្ហាដដែល ។

ក្នុងករណីសមាជិកក្រុមប្រឹក្សារូបណា មានមតិក្រៅពីប្រធានបទ ប្រធានអង្គប្រជុំត្រូវរំលឹកឱ្យមានមតិតែពីបញ្ហាដែលកំពុងពិភាក្សា។ ក្នុងករណីដែលប្រធានក្រើនរំលឹកហើយ សមាជិកនោះនៅតែពុំព្រមអនុវត្តតាម ប្រធានអង្គប្រជុំមានសិទ្ធិបញ្ឈប់ការមានមតិរបស់សមាជិកនោះ។ ករណីកាន់តែធ្ងន់ធ្ងរជាងនេះ ប្រធានអង្គប្រជុំត្រូវបណ្តេញសមាជិករូបនោះចេញពីអង្គប្រជុំសម្រាប់របៀបវារៈដែលកំពុងតែពិភាក្សានោះ។ ចំពោះរបៀបវារៈផ្សេងពីនេះ សមាជិកដែលត្រូវបណ្តេញចេញនោះមានសិទ្ធិចូលរួមប្រជុំជាធម្មតាវិញបាន ។

**ប្រការ ១៣.–**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំទីកន្លែងឱ្យបានសមស្រប ដោយធ្វើការបែងចែកឱ្យបានច្បាស់លាស់អំពីទីកន្លែងសម្រាប់សមាជិកក្រុមប្រឹក្សា គណៈអភិបាល អ្នកពាក់ព័ន្ធ និងសម្រាប់សាធារណជន ។ ការរៀបចំកន្លែងអង្គុយរបស់សមាជិកក្រុមប្រឹក្សាម្នាក់ៗត្រូវរៀបតាមលំដាប់អាយុ ដោយផ្តល់អាទិភាពឱ្យអ្នកដែលមានអាយុច្រើនជាងគេអង្គុយខាងមុខ ។

**ប្រការ ១៤.–**

រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ត្រូវអនុញ្ញាតឱ្យតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ យ៉ាងច្រើនពីរ(០២)រូប និងប្រធានគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាដើម្បីចូលរួម លើកលែងតែកិច្ចប្រជុំដូចមានកំណត់ក្នុងប្រការ៧ នៃបទបញ្ជាផ្ទៃក្នុងនេះ ។

## ជំពូកទី ៣

## អំពីដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា

**ប្រការ ១៥.–**

ក្នុងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើដីកា ឬសេចក្តីសម្រេចនានា តាមការចាំបាច់ទាក់ទិននឹង :

១- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

៣- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

៤- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាពនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ក្រុមប្រឹក្សាប្រភេទផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា

៥- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

៦- បញ្ហាហិរញ្ញវត្ថុផ្សេងទៀត

៧- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

៨- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

៩- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋ

១០- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើង ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**ប្រការ ១៦.–**

ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចយកជាការបាន លុះត្រាតែដីកា និង សេចក្តីសម្រេចនោះ ត្រូវបានអនុម័តដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ។

ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានអង្គប្រជុំក្រុមប្រឹក្សាមានឧត្តមានុភាព ។

សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របជាមួយបទបញ្ជាផ្ទៃក្នុងនេះ នឹងពុំមានសុពលភាពឡើយ ។

ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទាំងឡាយណាដែលខុសច្បាប់ ដីកានិងសេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ ។

**ប្រការ ១៧.–**

ការបោះឆ្នោតត្រូវធ្វើឡើងដោយការលើកដៃ លើកលែងតែក្នុងការអនុម័តដូចមានចែងក្នុងប្រការ៩១ នៃបទបញ្ជាផ្ទៃក្នុងនេះ។ លទ្ធផលនៃការបោះឆ្នោតអនុម័ត ត្រូវប្រកាសភ្លាមៗនូវចំនួនសម្លេងយល់ព្រម សម្លេងជំទាស់ និងសម្លេងអនុប្បវាទ ហើយត្រូវកត់ត្រាក្នុងកំណត់ហេតុ។

**ប្រការ ១៨.–**

សមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី(១/៣) នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល អាចស្នើសុំធ្វើការកែប្រែដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។

សំណើសុំកែប្រែនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការស្នើសុំកែប្រែនេះ។ សមាជិកដែលស្នើសុំ ត្រូវដាក់ជូនសំណើនេះនៅក្នុងអំឡុងនៃកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ឬអាចដាក់ជូនទៅនាយករដ្ឋបាលដើម្បីរាយការណ៍ជូនប្រធានក្រុមប្រឹក្សា។ ក្រុមប្រឹក្សាត្រូវចាត់ឱ្យធ្វើការសិក្សាអំពីសំណើនេះ ហើយត្រូវដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញបន្ទាប់ ឬកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់ ។

**ប្រការ ១៩.–**

ប្រធានអង្គប្រជុំត្រូវចាត់ឱ្យធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីដីកា និងសេចក្តីសម្រេច ដែលត្រូវបានក្រុមប្រឹក្សាអនុម័ត។

ដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវបិទផ្សាយនៅលើក្តារខៀនព័ត៌មានសាធារណៈរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ដែលមាននៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ យ៉ាងយឺតបំផុតរយៈពេលប្រាំ (០៥) ថ្ងៃការងារ បន្ទាប់ពីថ្ងៃអនុម័ត ។

## ជំពូកទី ៤

## អំពីសិទ្ធិអំណាចរបស់ប្រធានក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សា

**ប្រការ ២០.–**

ប្រធានក្រុមប្រឹក្សា ត្រូវធ្វើជាប្រធានអង្គប្រជុំទាំងអស់របស់ក្រុមប្រឹក្សា ។

ក្នុងករណីប្រធានក្រុមប្រឹក្សាអវត្តមាន សមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សា ត្រូវធ្វើជាប្រធានអង្គប្រជុំ ។

ក្នុងករណីសមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលំដាប់បន្ទាប់នៃបញ្ជីបេក្ខជនជាមួយប្រធានក្រុមប្រឹក្សា អវត្តមាន សមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនជាប់ឆ្នោតលំដាប់ទី២ ក្នុងក្រុមប្រឹក្សា ត្រូវធ្វើជាប្រធានអង្គប្រជុំ ។

ក្នុងករណីសមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលើគេនៃបញ្ជីបេក្ខជនជាប់ឆ្នោតលំដាប់ទី២ ក្នុងក្រុមប្រឹក្សា អវត្តមាន សមាជិកក្រុមប្រឹក្សាដែលស្ថិតនៅលេខរៀងលំដាប់បន្តបន្ទាប់នៃបញ្ជីបេក្ខជនជាមួយនោះ ត្រូវធ្វើជាប្រធានអង្គប្រជុំ ។

**ប្រការ ២១.—**

ប្រធានក្រុមប្រឹក្សាមានភារកិច្ច :

១- ធានាឱ្យគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រព្រឹត្តទៅក្នុងលក្ខណៈប្រជាធិបតេយ្យ មិនលំអៀង មានរបៀបរៀបរយ និងគ្មានការរំខាន

២- បង្កលក្ខណៈឱ្យសមាជិកក្រុមប្រឹក្សាអាចបញ្ចេញមតិ យោបល់ ស្របទៅតាមការកំណត់ដូចមានចែងក្នុងប្រការ ១១ នៃបទបញ្ជាផ្ទៃក្នុងនេះ

៣- ត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សា

៤- តំណាងឱ្យក្រុមប្រឹក្សា ក្នុងការចាត់ចែង និងទំនាក់ទំនងការងារនានា នៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចនៃក្រុមប្រឹក្សារបស់ខ្លួន ។

**ប្រការ ២២.—**

សមាជិកក្រុមប្រឹក្សា មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន ។

គ្មានសមាជិកក្រុមប្រឹក្សាណាម្នាក់ត្រូវបានចាប់ខ្លួន ឬ ឃុំខ្លួន ឬ ប្រឈមនឹងសកម្មភាព ឬចំណាត់ការណាមួយ ដោយសារតែហេតុផលនៃការបញ្ចេញមតិ ឬ ការបោះឆ្នោតរបស់ខ្លួនក្នុងអង្គប្រជុំក្រុមប្រឹក្សាឡើយ ។

សមាជិកក្រុមប្រឹក្សាគ្រប់រូបមិនអាចបញ្ចេញមតិយោបល់ក្នុងនាមក្រុមប្រឹក្សាទាំងមូលបានទេ ប្រសិនបើគ្មានការអនុញ្ញាតពីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បន្ទាប់ពីកិច្ចប្រជុំ ។

**ប្រការ ២៣.—**

ប្រធានក្រុមប្រឹក្សា អាចអញ្ជើញអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានបំណុលពន្ធមន្ទីរ អង្គភាព ឬ អ្នកពាក់ព័ន្ធនានា ឱ្យចូលរួមក្នុងកិច្ចប្រជុំណាមួយក៏បាន តាមការចាំបាច់ ។

អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានឬតំណាងមន្ទីរអង្គភាព ឬអ្នកពាក់ព័ន្ធនានា ដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំមានសិទ្ធិបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាបាន តែមិនអាចធ្វើការបោះឆ្នោតអនុម័តបានឡើយ។

**ប្រការ ២៤.–**

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចកោះអញ្ជើញគណៈអភិបាល ឬ អភិបាល និងបុគ្គលិកក្រុមប្រឹក្សាដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំសាមញ្ញ ឬ វិសាមញ្ញរបស់ក្រុមប្រឹក្សា។

គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សាអាចចោទសួរទៅអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អំពីស្ថានភាពនៃការអនុវត្តសេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា ព្រមទាំងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល។

**ប្រការ ២៥.–**

គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុញ្ញាតឱ្យសាធារណជនចូលរួមបានទៅតាមចំនួនកន្លែងដែលមាន លើកលែងតែកិច្ចប្រជុំសម្ងាត់ ដូចមានចែងក្នុងប្រការ៧ នៃបទបញ្ជាផ្ទៃក្នុងនេះ។

**ប្រការ ២៦.–**

ប្រធានអង្គប្រជុំ មានសិទ្ធិបណ្តេញសមាជិកក្រុមប្រឹក្សា គណៈអភិបាល អ្នកពាក់ព័ន្ធ និង/ឬ សាធារណជន ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលជននោះចចេសរឹងរូស ធ្វើឱ្យខូចរបៀបរៀបរយនៃអង្គប្រជុំរបស់ក្រុមប្រឹក្សា បន្ទាប់ពីប្រធានអង្គប្រជុំបានដាស់តឿនជាញឹកញាប់ ដើម្បីស្នើសុំឱ្យរក្សារបៀបរៀបរយក្នុងកិច្ចប្រជុំ។

## ជំពូកទី ៥

## អំពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សា

**ប្រការ ២៧.–**

គណៈកម្មាធិការរបស់ក្រុមប្រឹក្សា ដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានដូចខាងក្រោម :

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងបី(០៣)ខាងលើនេះត្រូវផ្អែកតាមអនុក្រឹត្យ ប្រកាសក្រសួងមហាផ្ទៃ និងប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការផ្សេងទៀតដើម្បីជួយការងាររបស់ក្រុមប្រឹក្សា តាមការចាំបាច់ ដោយផ្អែកតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១១៥ មាត្រា១១៦ មាត្រា ១១៧ មាត្រា ១១៨ មាត្រា១១៩ មាត្រា១២០ មាត្រា១២១ និងមាត្រា១២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**ប្រការ ២៨.—**

ដើម្បីពិភាក្សាលើបញ្ហាណាមួយដែលអាចដាក់បញ្ចូលក្នុងរបៀបវារៈប្រជុំរបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាអាចចាត់ឱ្យគណៈកម្មាធិការណាមួយដែលមានភារកិច្ចពាក់ព័ន្ធនឹងបញ្ហានោះ ធ្វើការសិក្សា ស្រាវជ្រាវ និងលើកយោបល់ជូនក្រុមប្រឹក្សារបស់ខ្លួន។

**ប្រការ ២៩.—**

ក្រុមប្រឹក្សា អាចចាត់ឱ្យគណៈកម្មាធិការច្រើនជាងមួយ ដើម្បីសហការគ្នាធ្វើការសិក្សាស្រាវជ្រាវ លើកយោបល់ លើបញ្ហាដែលពាក់ព័ន្ធគ្នា ដាក់ជូនក្រុមប្រឹក្សាពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

គណៈអភិបាល និងនាយករដ្ឋបាល ត្រូវផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងលេខាធិការដ្ឋាន ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការក្នុងអំឡុងពេលដែលគណៈកម្មាធិការធ្វើការសិក្សា ស្រាវជ្រាវខាងលើនេះ។

## ជំពូកទី ៦

## អំពីតួនាទី ភារកិច្ច និងសិទ្ធិរបស់គណៈអភិបាល និងនាយករដ្ឋបាល

**ប្រការ ៣០.—**

អភិបាល និង/ ឬ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចស្នើសុំទៅប្រធានក្រុមប្រឹក្សា ដើម្បីដាក់បញ្ចូលរបៀបវារៈណាមួយទៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងអាចស្នើកោះប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា ដើម្បីពិនិត្យ ពិភាក្សា និងអនុម័តលើកិច្ចការពិសេស និងបន្ទាន់ណាមួយដែលច្បាប់ និងលិខិតបទដ្ឋាននានា តម្រូវឱ្យសុំការសម្រេចពីក្រុមប្រឹក្សា។

**ប្រការ ៣១.—**

គណៈអភិបាល ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីលទ្ធផលនៃការអនុវត្តដីកា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ព្រមទាំងសកម្មភាពដែលបានអនុវត្តដោយគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ក្នុងចន្លោះអង្គប្រជុំសាមញ្ញមួយ ទៅអង្គប្រជុំសាមញ្ញមួយ ។

**ប្រការ ៣២.—**

នាយករដ្ឋបាល ត្រូវធ្វើជាជំនួយការឱ្យក្រុមប្រឹក្សាក្នុងការរៀបចំរបៀបវារៈនៃកិច្ចប្រជុំ ឯកសារពាក់ព័ន្ធនានា លិខិតអញ្ជើញ និងធ្វើកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ។

**ប្រការ ៣៣.–**

នាយករដ្ឋបាល ត្រូវថែរក្សាឱ្យបានគង់វង្ស នូវឯកសារចំលងនៃរបៀបវារៈកិច្ចប្រជុំ ឯកសារ កំណត់ហេតុ និងអាគិកាសំខាន់ៗនៃកិច្ចប្រជុំ ដើម្បីឱ្យសាធារណជនអាចពិនិត្យមើល ឬចម្លងចែកជូនសាធារណជន ដែលបានលើកឡើងស្នើសុំ ដោយត្រូវបង់ថ្លៃ ត្រឹមថ្លៃនៃការថតចម្លងឯកសារ ។

## ជំពូកទី ៧
## អំពីកំណត់ហេតុនៃកិច្ចប្រជុំ

**ប្រការ ៣៤.–**

កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាត្រូវកត់ត្រានូវបញ្ហាដូចខាងក្រោម :

១- ទីកន្លែង និងកាលបរិច្ឆេទ ( ថ្ងៃខែឆ្នាំ និងម៉ោង) នៃកិច្ចប្រជុំ

២- ការបញ្ជាក់អះអាងថាការប្រជុំមានលក្ខណៈស្របច្បាប់ ( កូរ៉ុម របៀបវារៈ ការបន្ថែមរបៀបវារៈ...)

៣- បញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាដែលមានវត្តមាន និងអវត្តមាន

៤- បញ្ជីឈ្មោះ និងអង្គភាពរបស់អ្នកដែលចូលរួមប្រជុំ ( ប្រសិនបើមាន)

៥- ចំនួនសាធារណជនដែលបានអញ្ជើញចូលរួម ( ប្រសិនបើមាន)

៦- សេចក្តីសម្រេច និងលទ្ធផលនៃការបោះឆ្នោតអនុម័តលើបញ្ហាផ្សេងៗក្នុងរបៀបវារៈនៃកិច្ចប្រជុំ រួមទាំងបញ្ហាដែលបានបន្ថែមនៅក្នុងរបៀបវារៈ

៧- របៀបវារៈ ពេលវេលា និងទីកន្លែងសម្រាប់កិច្ចប្រជុំលើកក្រោយ

៨- បញ្ហាផ្សេងៗទៀតដែលត្រូវកត់ត្រា

៩- ពេលវេលាបិទអង្គប្រជុំ ។

**ប្រការ ៣៥.–**

កំណត់ហេតុនៃកិច្ចប្រជុំត្រូវកត់ត្រានូវពាក្យពេចន៍ និងឃ្លាប្រយោគសំខាន់ៗនៃកិច្ចពិភាក្សា ដោយមិនត្រូវកត់ត្រាសង្ខេបខ្លាំងពេកនាំឱ្យបាត់បង់នូវខ្លឹមសារនៃកិច្ចប្រជុំឡើយ ។

**ប្រការ ៣៦.–**

សេចក្តីព្រាងកំណត់ហេតុ ត្រូវតែចែកជូនដល់សមាជិកក្រុមប្រឹក្សាគ្រប់រូបយ៉ាងតិចចំនួនបី(០៣) ថ្ងៃមុនកិច្ចប្រជុំបន្ទាប់ ។

**ប្រការ ៣៧.–**

សេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំសាមញ្ញ ឬកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា ត្រូវដាក់បញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញបន្ទាប់ ដើម្បីអនុម័ត ។

នាយករដ្ឋបាល ត្រូវទទួលបន្ទុកថតចម្លងកំណត់ហេតុដែលបានអនុម័ត រួចចែកជូនគ្រប់សមាជិកក្រុមប្រឹក្សាទាំងអស់ បញ្ជូនមកក្រសួងមហាផ្ទៃ និងរក្សាទុកជាឯកសារ ។

## ជំពូកទី ៨

## អំពីការខកខានមិនបានចូលរួមប្រជុំ

**ប្រការ ៣៨.—**

សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គ្រប់រូបត្រូវតែចូលរួមក្នុងគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ។

ក្នុងករណីមានធុរៈមិនអាចចូលរួមប្រជុំបាន សមាជិកក្រុមប្រឹក្សាត្រូវដាក់ពាក្យសុំអនុញ្ញាតជាលាយលក្ខណ៍អក្សរជូនប្រធានក្រុមប្រឹក្សាយ៉ាងតិចមួយ(០១)ថ្ងៃ មុនកិច្ចប្រជុំ ។

ក្នុងករណីសមាជិកក្រុមប្រឹក្សាណាម្នាក់ដើរចេញពីអង្គប្រជុំត្រូវចាត់ទុកជាអវត្តមានដោយគ្មានច្បាប់មួយដង ។

**ប្រការ ៣៩.—**

នៅក្នុងគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាត្រូវស្រង់ឈ្មោះសមាជិកក្រុមប្រឹក្សាដែលវត្តមាន សមាជិកក្រុមប្រឹក្សាដែលអវត្តមាន ដោយបញ្ជាក់អំពីមូលហេតុអវត្តមាននោះឱ្យបានច្បាស់លាស់ ។

**ប្រការ ៤០.—**

ប្រធានក្រុមប្រឹក្សា អាចអនុញ្ញាតច្បាប់ឱ្យសមាជិកក្រុមប្រឹក្សាអវត្តមានក្នុងកិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាបានតែមួយលើកប៉ុណ្ណោះ ។ ក្នុងករណីស្នើសុំឈប់សម្រាកពីរ(០២)លើកជាប់ៗគ្នា ត្រូវសុំឱ្យក្រុមប្រឹក្សាអនុម័ត ។

**ប្រការ ៤១.—**

សមាជិកក្រុមប្រឹក្សាដែលអវត្តមានក្នុងកិច្ចប្រជុំសាមញ្ញចំនួនពីរ(០២)លើកជាប់ៗគ្នាដោយមានជំងឺ ត្រូវមានឯកសារបញ្ជាក់ពីគ្រូពេទ្យ ។

**ប្រការ ៤២.—**

សមាជិកក្រុមប្រឹក្សាណាម្នាក់ ក្រោយពីទទួលបានលិខិតអញ្ជើញដូចមានចែងនៅក្នុងប្រការ៣ និងប្រការ៤ នៃបទបញ្ជាផ្ទៃក្នុងនេះហើយ តែមិនបានចូលរួមប្រជុំដោយគ្មានការអនុញ្ញាត សមាជិកក្រុមប្រឹក្សារូបនោះត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងនៅក្នុងប្រការ៤៤ នៃបទបញ្ជាផ្ទៃក្នុងនេះ ។

## ជំពូកទី ៩
## អំពីវិន័យ

**ប្រការ ៤៣.—**

សមាជិកក្រុមប្រឹក្សាក្រុងរួម ត្រូវគោរពវិន័យដូចខាងក្រោម :

- គោរពបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឱ្យបានខ្ជាប់ខ្ជួន
- គោរពតាមការណែនាំ និងការចាត់ចែងរបស់ប្រធានអង្គប្រជុំ
- ទទួលខុសត្រូវអំពីកិច្ចការ អំពើរបស់ខ្លួនដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់ ក្រុមប្រឹក្សា

**ប្រការ ៤៤.—**

ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សា មានដូចតទៅ :

- ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាដែលខកខានមកប្រជុំដោយគ្មានច្បាប់អនុញ្ញាត
- ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំ។

**ប្រការ ៤៥.—**

ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សាដែលខកខានមកប្រជុំ ដោយគ្មានច្បាប់អនុញ្ញាតមានដូចតទៅ :

- ប្រសិនបើខកខានមិនបានមកប្រជុំដោយគ្មានច្បាប់អនុញ្ញាតចំនួនមួយ(០១)លើក ត្រូវទទួលការក្រើនរំលឹកពីប្រធានក្រុមប្រឹក្សា និងត្រូវចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំនោះ។
- ប្រសិនបើខកខានមិនបានមកប្រជុំដោយគ្មានច្បាប់អនុញ្ញាតចំនួនពីរ(០២)លើកមិនជាប់គ្នាក្នុងអំឡុងពេល ១២ខែ ត្រូវទទួលការក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុ និងត្រូវកាត់ប្រាក់បំណាច់ចំនួនម្ភៃប្រាំ (២៥) ភាគរយនៃខែអវត្តមានលើកទី២
- ប្រសិនបើខកខានមិនបានមកប្រជុំដោយគ្មានច្បាប់អនុញ្ញាតចំនួនបី(០៣)លើក មិនជាប់គ្នាក្នុងអំឡុងពេល១២ខែ ត្រូវទទួលការស្តីបន្ទោសជាលាយលក្ខណ៍អក្សរ និងត្រូវកាត់ប្រាក់បំណាច់ចំនួនហាសិប(៥០)ភាគរយ នៃខែអវត្តមានលើកទី៣។ ក្នុងករណីអនុវត្តទណ្ឌកម្មខាងវិន័យខាងលើនេះរួចហើយ សាមីខ្លួនមិនព្រមរាងចាល ក្រុមប្រឹក្សាត្រូវដាក់ករណីនេះទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួន ដើម្បីអនុម័តបណ្តេញសមាជិកនោះចេញពីក្រុមប្រឹក្សារបស់ខ្លួន។
- ប្រសិនបើខកខានមិនបានមកប្រជុំសាមញ្ញដោយគ្មានច្បាប់អនុញ្ញាតចំនួនពីរ(០២)លើកជាប់ៗគ្នា ត្រូវបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា។

ប្រធានក្រុមប្រឹក្សា ត្រូវចាត់ចែងធ្វើជាលាយលក្ខណ៍អក្សរនូវរាល់ការក្រើនរំលឹក ការស្តីបន្ទោស ការដាក់វិន័យ និងការបណ្តេញពីសមាជិកក្រុមប្រឹក្សា ឱ្យដល់លំនៅដ្ឋាននៃសមាជិកក្រុមប្រឹក្សាដែលទទួលទណ្ឌកម្មខាងវិន័យនោះ។

**ប្រការ ៤៦.—**

ប្រាក់ដែលបានមកពីការពិន័យ ត្រូវដាក់បញ្ចូលជាថវិការបស់ក្រុមប្រឹក្សា ។

**ប្រការ ៤៧.—**

ទណ្ឌកម្មខាងវិន័យចំពោះសមាជិកក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំ មានដូចតទៅ :

- ក្រើនរំលឹក
- ក្រើនរំលឹកដោយចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំ
- បណ្តេញចេញពីអង្គប្រជុំ

**ប្រការ ៤៨.—**

ប្រធានអង្គប្រជុំត្រូវក្រើនរំលឹកចំពោះសមាជិកក្រុមប្រឹក្សាណា ដែលមានមតិក្រៅពីប្រធានបទដែលកំពុងពិភាក្សា ឬ មានមតិលើសពីរយៈពេលដែលអនុញ្ញាតដោយប្រធានអង្គប្រជុំ ។

ក្នុងករណីទទួលការក្រើនរំលឹកចំនួនមួយ(០១)ដងហើយ សមាជិករូបនោះនៅតែប្រព្រឹត្តិខុសឆ្គងថែមទៀត ប្រធានអង្គប្រជុំត្រូវក្រើនរំលឹកម្តងទៀត និងត្រូវចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំអំពីការក្រើនរំលឹកនោះ ។ ករណី សមាជិករូបនោះនៅតែប្រព្រឹត្តិខុសឆ្គងម្តងទៀត ប្រធានអង្គប្រជុំត្រូវបញ្ឈប់ការមានមតិរបស់សមាជិករូបនោះ ។

ករណីបញ្ឈប់មិនឱ្យមានមតិ តែសមាជិករូបនោះនៅតែចចេសរឹងរូស ប្រធានអង្គប្រជុំត្រូវចាត់វិធានការបណ្តេញសមាជិកនោះចេញពីអង្គប្រជុំក្រុមប្រឹក្សា ។

**ប្រការ ៤៩.—**

ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា បើមានសមាជិកណា បង្កភាពច្របូកច្របល់ ឬនាំអាទិ៍ដល់សមាជិកក្រុមប្រឹក្សាផ្សេងទៀតឱ្យបង្កភាពច្របូកច្របល់ក្នុងកិច្ចប្រជុំ ឬជេរប្រមាថមើលងាយ ឬបង្កជម្លោះ ឬ គំរាមកំហែងសមាជិកក្រុមប្រឹក្សាដទៃទៀតក្នុងកិច្ចប្រជុំ ប្រធានអង្គប្រជុំត្រូវចាត់វិធានការឱ្យសមាជិករូបនោះ គោរពបទបញ្ជាផ្ទៃក្នុង និងរក្សារបៀបរៀបរយនៃកិច្ចប្រជុំ។ ក្នុងករណីដែលសមាជិកនោះនៅតែចចេសរឹងរូសមិនព្រមគោរពតាមបទបញ្ជាផ្ទៃក្នុង ប្រធានអង្គប្រជុំត្រូវចាត់វិធានការដោយចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំ និងត្រូវបណ្តេញសមាជិកនោះចេញពីអង្គប្រជុំ ។

ប្រធានអង្គប្រជុំអាចប្រកាសលើកពេលប្រជុំបាន ប្រសិនបើអង្គប្រជុំមានកើតឡើងនូវភាពច្របូកច្របល់ ចលាចលដែលមិនអាចឱ្យអង្គប្រជុំដំណើរការទៅបាន ។

**ប្រការ ៥០.—**

ប្រធានអង្គប្រជុំត្រូវរក្សាការពារកុំឱ្យមានភាពច្របូកច្របល់នៅខាងក្នុង និងខាងក្រៅកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ។ ដើម្បីធ្វើឱ្យសម្រេចកិច្ចការនេះ ប្រធានអង្គប្រជុំអាចប្រើប្រាស់កំលាំងនគរបាល ឬកងរាជអាវុធហត្ថ នៅក្នុងមូលដ្ឋានរបស់ខ្លួន តាមការជាក់ស្តែង ។

**ប្រការ ៥១.–**

ការបញ្ឈប់ពីតំណែងចំពោះសមាជិកក្រុមប្រឹក្សាណាម្នាក់ដែលមិនគោរពបទបញ្ជាផ្ទៃក្នុងនេះ ក្រុមសីលធម៌របស់ក្រុមប្រឹក្សា និងការស្នើសុំដកហូតអភិបាល អភិបាលរងណាម្នាក់ចេញពីមុខតំណែង ដូចមានចែងក្នុងមាត្រា ១៥២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើតាមវិធីបោះឆ្នោតជាសម្ងាត់ ដោយយកសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ។ (មានគំរូសន្លឹកឆ្នោតជូនភ្ជាប់មកជាមួយ) ។

## ជំពូកទី ១០

## អំពីការកែប្រែ និងការផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុង

**ប្រការ ៥២.–**

សមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី(១/៣) នៃសមាជិកក្រុមប្រឹក្សាទាំងអស់ មានសិទ្ធិស្នើសុំដើម្បីកែប្រែបទបញ្ជាផ្ទៃក្នុងនេះបាន ។

សំណើសុំកែប្រែបទបញ្ជាផ្ទៃក្នុង ត្រូវអនុម័តដោយសម្លេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល ហើយត្រូវលើកយកមកពិភាក្សា សម្រេច នៅក្នុងកិច្ចប្រជុំសាមញ្ញបន្ទាប់របស់ក្រុមប្រឹក្សា ។

**ប្រការ ៥៣.–**

នាយករដ្ឋបាល ទទួលភារកិច្ចក្នុងការថតចម្លងបទបញ្ជាផ្ទៃក្នុង ឬ ខ្លឹមសារ នៃការកែប្រែបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាផ្ញើជូនគ្រប់សមាជិកក្រុមប្រឹក្សាទាំងអស់ ក្រសួងមហាផ្ទៃ និងអ្នកពាក់ព័ន្ធ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៥៤.–**

បទបញ្ជាផ្ទៃក្នុងនេះត្រូវចូលជាធរមានភ្លាម បន្ទាប់ពីបានអនុម័តដោយក្រុមប្រឹក្សា ។

......................ថ្ងៃទី........ខែ............ឆ្នាំ២០០...

**ប្រធានក្រុមប្រឹក្សា**

*កំណត់សំគាល់ : ពាក្យ "រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ" ក្នុងគំរូបទបញ្ជាផ្ទៃក្នុងនេះ នៅពេលក្រុមប្រឹក្សាអនុម័តជាផ្លូវការ ត្រូវជំនួសដោយឈ្មោះជាក់លាក់នៃរដ្ឋបាលរបស់ខ្លួន ឧទាហរណ៍: ក្រុមប្រឹក្សារាជធានីភ្នំពេញ ។*

(គំរូ)

## សន្លឹកឆ្នោត

## សម្រាប់ការបោះឆ្នោតសម្ងាត់របស់ក្រុមប្រឹក្សា

យល់ព្រម :........................................ ☐

មិនយល់ព្រម :........................................ ☐

អនុប្បវាទ :........................................ ☐